សកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ

# របាយការណ៍សង្ខេបពីលទ្ធផលនៃការស្ទង់មតិ

# “បទពិសោធការសិក្សាតាមរយៈប្រព័ន្ធអេឡិចត្រូនិក របស់សិស្ស និស្សិតនៅកម្ពុជា”



ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០

## ១. សេចក្ដីផ្ដើម

របាយការណ៍សង្ខេបនេះ ត្រូវបានរៀបរៀងឡើងចេញពីលទ្ធផលនៃការស្ទង់មតិរបស់សិស្ស និស្សិត និងឪពុកម្ដាយ ឬ អាណាព្យាបាលតាមប្រព័ន្ធអ៊ិនធើណែតដែលមានរយៈពេល៣សប្ដាហ៍ គឺចាប់ពីថ្ងៃទី៤ ខែមេសា រហូតដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០។ ការស្ទង់មតិនេះ ធ្វើឡើងក្នុងគោលបំណងស្វែងយល់ពីបទពិសោធរបស់សិស្ស និស្សិតនៅក្នុងប្រទេសកម្ពុជា ទៅលើការរៀនតាមប្រព័ន្ធអេឡិចត្រូនិក ឬ (E-learning) បន្ទាប់ពីការប្រកាសដាក់ឲ្យអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា។ [1-2]

ក្រុមការងារនៃសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ សូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់សិស្ស និស្សិត ព្រមទាំងឪពុកម្ដាយ ឬ អាណាព្យាបាលគ្រប់រូប ដែលបានចូលរួមក្នុងការស្ទង់មតិមួយនេះ។

របាយការណ៍នេះ ជាការចូលរួមចំណែកតូចមួយពីក្រុមការងារសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវសេវាអប់រំសាធារណៈ ដែលមានគុណភាពសម្រាប់គ្រប់គ្នានៅក្នុងប្រទេសកម្ពុជា។

## ២. អំពីរបាយការណ៍ និងកម្រិតភាព

របាយការណ៍សង្ខេបនេះ ចែកចេញជាបួនផ្នែក៖ ផ្នែកទីមួយអំពីសេចក្ដីផ្ដើម ផ្នែកទីពីររៀបរាប់ពីរបាយការណ៍ និងកម្រិតភាព។ ផ្នែកទីបីគ្របដណ្ដប់នូវរបកគំហើញសង្ខេប និងផ្នែកទីបួនអំពីមតិយោបល់របស់សិស្ស និស្សិត និងឪពុកម្ដាយ ឬ អាណាព្យាបាល។

លទ្ធផលនៅក្នុងរបាយការណ៍មិនតំណាងឲ្យសម្លេង ឬ បទពិសោធរបស់សិស្ស និស្សិតនៅទូទាំងប្រទេសកម្ពុជានោះទេ។ របាយការណ៍នេះ គ្របដណ្ដប់បទពិសោធនៃសិស្ស និស្សិត និងឪពុកម្ដាយ ឬ អាណាព្យាបាលដែលបានចូលរួមនៅក្នុងការស្ទង់មតិមួយនេះ។ ក្រុមការងារយើងខ្ញុំ លើកទឹកចិត្តឲ្យមានការសិក្សាស៊ីជម្រៅដែលមានវិសាលភាពទូលំទូលាយគ្របដណ្ដប់ទៅលើបទពិសោធរបស់សិស្ស និស្សិតដោយស្ថាប័នដែលកំពុងធ្វើការងារយ៉ាងសកម្មលើវិស័យនេះ។

---

1 សេចក្ដីប្រកាសព័ត៌មានស្ដីពីការរៀនតាមប្រព័ន្ធអេឡិចត្រូនិក (E-learning) សម្រាប់ជំនួយដល់សិស្សានុសិស្សចុះនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០។

2 សេចក្ដីប្រកាសព័ត៌មានស្ដីពីការអនុវត្តវិស្សមកាលតូច មិនមានកាលកំណត់សម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ និងឯកជននៅរាជធានីភ្នំពេញ និងក្រុងសៀមរាបចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ក្នុងបរិបទនៃការ រីករាលដាលនៃជំងឺកូវីដ១៩។

## ៣. របកគំហើញសង្ខេប

### ក. ព័ត៌មានអំពីសិស្ស និស្សិត និង ឪពុកម្ដាយ ឬ អាណាព្យាបាល

បំពេញដោយ




អ្នកចូលរួមក្នុងការស្ទង់មតិ មានចំនួនសរុប១៨៧នាក់។ ក្នុងនោះ ៦៩ភាគរយ ជាសិស្ស និស្សិត និង៣១ភាគរយ ជាឪពុកម្ដាយ ឬ អាណាព្យាបាល។

លំនៅឋានបច្ចុប្បន្ន(បំពេញដោយ សិស្ស និស្សិត)




ជិត៦០ភាគរយនៃសិស្ស និស្សិតដែលចូលរួមក្នុងការស្ទង់មតិ គឺជាស្ត្រីមានទីលំនៅបច្ចុប្បន្ននៅក្នុងទីក្រុងភ្នំពេញ។ ពួកគេមានអាយុចន្លោះពី១៨ ទៅ២៤ឆ្នាំ។

មុខរបររបស់ឪពុកម្តាយ ឬ អាណាព្យាបាល




ចំនួនកូន ប្អូន ឬក្មួយដែលកំពុងនៅសិក្សា




ភាគច្រើននៃឪពុកម្តាយ ឬ អាណាព្យាបាលដែលចូលរួមក្នុងការស្ទង់មតិគឺជាបុរស ជាឪពុក និងមានមុខរបរជាមន្ត្រីរាជការ ហើយពួកគាត់កំពុងរស់នៅក្នុងទីក្រុងភ្នំពេញ។ ក្រោម៤០ភាគរយមានកូន ឬក្មួយអាយុចន្លោះពី១៣ ទៅ ១៨ឆ្នាំ។ ឪពុកម្តាយ ឬ អាណាព្យាបាល ជិត៦០ភាគរយ មានកូនកំពុងសិក្សាចន្លោះពី២ ទៅ៣នាក់ និងមានអាយុចន្លោះពី៦ ទៅ ១២ឆ្នាំ។

## ខ. ព័ត៌មានអំពីការសិក្សា

ជិតពាក់កណ្តាលនៃសិស្ស និស្សិត បំពេញថាពួកគេកំពុងសិក្សានៅកម្រិតមហាវិទ្យាល័យ និងជិត៤០ភាគរយផ្សេងទៀត ឆ្លើយថាពួកគេកំពុងរៀននៅកម្រិតវិទ្យាល័យ។ ជុំវិញគ្រឹះស្ថានអប់រំ៦៥ភាគរយនៃសិស្សនិស្សិតប្រាប់ថាពួកគេកំពុងរៀននៅគ្រឹះស្ថានអប់រំសាធារណៈរបស់រដ្ឋសាលារដ្ឋ) និង២១ភាគរយផ្សេងទៀត កំពុងរៀននៅគ្រឹះស្ថានអប់រំឯកជន(សាលាឯកជន)។ ចំណែកឯ ឪពុកម្តាយ ឬ អាណាព្យាបាល ៦០ភាគរយឆ្លើយថា ពួកគេមានកូន ឬ ក្មួយកំពុងរៀននៅកម្រិតបឋមសិក្សា និង២០ភាគរយ មានកូន ឬក្មួយកំពុងសិក្សានៅកម្រិតវិទ្យាល័យ។ ស្រដៀងគ្នាទៅនឹងសិស្ស និស្សិតផងដែរ ឪពុកម្តាយ ឬអាណាព្យាបាល ៤៩ភាគរយ បំពេញថាកូន ឬក្មួយរបស់ពួកគេកំពុងសិក្សានៅ

កំពុងសិក្សានៅក្នុងគ្រឹះស្ថានអប់រំ (បំពេញដោយសិស្ស និស្សិត)




កំពុងសិក្សានៅក្នុងគ្រឹះស្ថានអប់រំរបស់កូន ប្អូន ឬក្មួយរបស់អ្នក



សាលារដ្ឋ និង៤០ភាគរយកំពុងរៀននៅសាលាឯកជន។

នៅប្រទេសកម្ពុជា ការអប់រំចំណេះដឹងទូទៅពីកម្រិតមត្តេយ្យដល់វិទ្យាល័យ នៅគ្រប់គ្រឹះស្ថានសាធារណៈរបស់រដ្ឋគឺដោយឥតគិតថ្លៃ។ ក៏ប៉ុន្តែសម្រាប់ការសិក្សានៅកម្រិតឧត្តមសិក្សា សិស្ស និស្សិត ឬ អាណាព្យាបាលត្រូវចំណាយទៅលើថ្លៃសិក្សារបស់កូនចៅពួកគេ។ ស្របគ្នាដែលសិស្ស និស្សិតលើស ៤០ភាគរយថា ពួកគេមិនចំណាយទៅលើថ្លៃសាលារៀន(រដ្ឋ)នោះទេ។ ដោយឡែកជិត៣០ភាគរយឆ្លើយថាពួកគេចំណាយចន្លោះពី៥០០ទៅដល់ ៦៩៩ដុល្លារ ក្នុងមួយឆ្នាំទៅលើថ្លៃសាលារៀន(រដ្ឋ)។ ការចំណាយនេះហាក់មានតម្លៃថ្លៃសម្រាប់សិស្ស និស្សិតមួយចំនួនដែលមានបញ្ហាជីវភាពដើម្បីបន្តការសិក្សានូវកម្រិតឧត្តមសិក្សា។ ប៉ុន្តែតម្លៃនេះនៅទាបនៅឡើយ បើប្រៀបធៀបជាមួយការចំណាយរបស់សិស្ស និស្សិត ១៤ភាគរយផ្សេងទៀតក្នុងការស្ទង់មតិនេះដែលប្រាប់ថាពួកគេចំណាយលើសពី ២៥០០ដុល្លារក្នុងមួយឆ្នាំ ទៅលើថ្លៃសាលារៀន(ឯកជន) របស់ពួកគេ។

ការចំណាយទៅលើថ្លៃសាលារដ្ឋប្រចាំឆ្នាំ (គិតជាប្រាក់ដុល្លារ) បំពេញដោយសិស្ស និស្សិត




ការចំណាយទៅលើថ្លៃសាលាឯកជនប្រចាំឆ្នាំ (គិតជាប្រាក់ដុល្លារ) បំពេញដោយសិស្ស និស្សិត




ការចំណាយទៅលើថ្លៃសាលារដ្ឋរបស់កូន ប្អូន ឬក្មួយរបស់អ្នកប្រចាំឆ្នាំ(គិតជាប្រាក់ដុល្លារ)




ការចំណាយទៅលើថ្លៃសាលាឯកជនរបស់កូន ប្អូន ឬក្មួយរបស់អ្នកប្រចាំឆ្នាំ(គិតជាប្រាក់ដុល្លារ)



ឪពុកម្ដាយ ឬ អាណាព្យាបាលជិតពាក់កណ្ដាលឆ្លើយថា ពួកគេមិនចំណាយទៅលើថ្លៃសិក្សារបស់កូន ឬ ក្មួយដែលកំពុងរៀននៅសាលា(រដ្ឋ) នោះទេ។ ឪពុកម្ដាយម្នាក់ក្នុងចំណោម៥នាក់ ចំណាយចន្លោះពី៣០១ ទៅ ៦៩៩ដុល្លារក្នុងមួយឆ្នាំទៅលើការអប់រំនៅក្នុងគ្រឹះស្ថានអប់រំសាធារណៈនេះផងដែរ។ ឪពុកម្ដាយ ឬ អាណាព្យាបាល ៣០ភាគរយនៅក្នុងការស្ទង់មតិតនេះឆ្លើយថា ពួកគេបានចំណាយលើសពី ២៥០០ដុល្លារទៅលើថ្លៃសាលារៀន(ឯកជន) របស់កូន ឬ ក្មួយពួកគេម្នាក់ក្នុងមួយឆ្នាំ។ សម្រាប់ឪពុក ម្ដាយមួយចំនួនគិតថាគុណភាពនៃការអប់រំ សុវត្ថិភាព និងការវិវដ្តរបស់កូនៗពួកគេ គឺជាកត្តាអទិភាព ហើយនៅពេលដែលពួកគេមានទំនុកចិត្តទៅលើប្រព័ន្ធអប់រំដែលផ្តល់ដោយឯកជន ជាហេតុនាំឲ្យពួកគេវិនិយោគ ឬ សម្រេចចិត្តចំណាយយ៉ាងច្រើនទៅលើការអប់រំរបស់កូនចៅរបស់ខ្លួននៅគ្រឹះស្ថានឯកជន។ ទោះជាយ៉ាងនេះក្តី សម្រាប់ប្រទេសដែលប្រជាជនមានចំណូលក្រោមមធ្យម (ចន្លោះពី១០២៦ ទៅ ៤០៣៥ដុល្លារ សម្រាប់ម្នាក់ក្នុងមួយឆ្នាំ)[3] ដូចជាប្រទេសកម្ពុជា ការចំណាយខាងលើរាប់បញ្ចូលទាំងការចំណាយទៅលើការអប់រំនៅគ្រឹះស្ថានសាធារណៈរបស់រដ្ឋពិសេសកម្រិតឧត្តមសិក្សា បានឆ្លុះបញ្ចាំងពី គម្លាតនៃវិសមភាព និងឧបសគ្គសម្រាប់សិស្ស និស្សិត ឬ ឪពុកម្ដាយមួយចំនួនធំ ទៅលើលទ្ធភាពក្នុងការបញ្ជូនកូនចៅរបស់ពួកគេទៅទទួលការអប់រំក្នុងតម្លៃថ្លៃបែបនេះ។ ដូចនេះ ការពង្រឹងគុណភាពអប់រំនៅគ្រឹះស្ថានសាធារណៈរបស់រដ្ឋគឺមានសារៈសំខាន់បំផុត ពិសេសក្នុងការធ្វើឲ្យប្រាកដថាគ្មាននរណាម្នាក់ត្រូវបានផាត់ចេញពីការអប់រំ។

## គ. បទពិសោធនៃការរៀនតាមប្រព័ន្ធអេឡិចត្រូនិក

សិស្ស និស្សិត និងឪពុកម្ដាយ ឬ អាណាព្យាបាលជាង៨០ភាគរយ ដឹងពីការរៀនតាមប្រព័ន្ធអេឡិចត្រូនិក ហើយពួកគេថាការរៀនតាមប្រព័ន្ធនេះផ្តល់អត្ថប្រយោជន៍ដល់ពួកគេ អត្ថប្រយោជន៍ទាំងនោះរួមមាន៖

ទី១. ពួកគេបានរៀនជំនាញថ្មី ពិសេសក្នុងការប្រើប្រាស់ប្រព័ន្ធអ៊ិនធើណែត។
ទី២. កសាងទំនុកចិត្តជាមួយប្រព័ន្ធអេឡិចត្រូនិក។
ទី៣. មានចំណេះដឹងក្នុងការទាញយកទិន្នន័យដែលត្រូវការ។
ទី៤. ទទួលបានព័ត៌មានថ្មីៗ និងចម្រុះ។
ទី៥. ពួកគេថាពួកគេអាចអនុវត្តន៍ភ្លាមៗ។

ម្នាក់ក្នុងចំណោមនោះ ឆ្លើយថា គេមិនចាំបាច់ស្លៀកសម្លៀកបំពាក់ឯកសណ្ឋាន និងប្រើឥរិយាបថតាមចិត្តនៅក្នុងពេលរៀនតាមប្រព័ន្ធនេះ។

---

[3] "កម្ពុជាក្លាយជាប្រទេសសេដ្ឋកិច្ចចំណូលក្រោមមធ្យម តើនេះមានយ៉ាងដូចម្ដេច?" សម្រង់អត្ថបទពីធនាគារពិភពលោក (បានអានព័ត៌មាន ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ ២០២០) https://blogs.worldbank.org/eastasiapacific/cambodia-is-now-a-lower-middle-income-economy-what-does-this-mean

**តើអ្នកធ្លាប់ជួបឧបសគ្គក្នុងការរៀនតាមប្រព័ន្ធអេឡិចត្រូនិចនេះដែររឺទេ?**




**តើកូន ប្អូន ឬក្មួយអ្នកធ្លាប់ជួបឧបសគ្គក្នុងការរៀនតាមប្រព័ន្ធអេឡិចត្រូនិចនេះដែររឺទេ?**




ទោះជាមានអត្ថប្រយោជន៍មួយចំនួន ត្រូវបានលើកឡើងយ៉ាងណាក៏ដោយ ក៏មានឧបសគ្គមួយចំនួនលើកឡើងផងដែរពីសំណាក់សិស្ស និស្សិត និងឪពុកម្ដាយ ឬ អាណាព្យាបាលភាគច្រើននៅក្នុងការស្ទង់មតិនេះ។ ឧបសគ្គទាំងនោះរួមមាន ការចំណាយប្រាក់កាសបន្ថែមទៅលើសេវាអ៊ិនធើណែត និងឧបករណ៍សិក្សាដូចជាកុំព្យូទ័រ ទូរស័ព្ទទំនើប អាយផែត ឬ ថេបប្លែត ជាដើម ការចំណាយពេលវេលាច្រើនពិសេសទៅលើភាពរអាក់រអួលនៃប្រព័ន្ធអ៊ិនធើណែត កត្តាជីវភាពគ្រួសារក្នុងអំឡុងពេលជំងឺកូវីដ១៩នេះ និងទីកន្លែងរស់នៅមិនអំណោយផលសម្រាប់ការរៀនតាមប្រព័ន្ធនេះ។ បន្ថែមពីលើឧបសគ្គខាងលើនេះ អ្នកបំពេញមួយចំនួនទៀតបានលើកឡើងថា ពួកគេមិនបានជួបមិត្តភ័ក្តិ និងមិនអាចសាកសួរគ្រូដោយផ្ទាល់ និងមានអារម្មណ៍តានតឹងដោយសារភាពស្មុគស្មាញនៃប្រព័ន្ធសិក្សានេះ។ ទន្ទឹមនឹងនេះ មួយចំនួនតូចផ្សេងទៀត លើកឡើងពីភាពមិនរួចរាល់របស់ពួកគេ ដោយសារតែមិនទទួលបានការណែនាំ ឬ មិនទាន់យល់ពីរបៀបរៀនតាមប្រព័ន្ធនេះជាមុន។

ឪពុកម្ដាយ ឬ អាណាព្យាបាលមួយចំនួនក៏បានបំពេញផងដែរថា ពួកគេមានអារម្មណ៍តានតឹងដោយសារត្រូវចំណាយពេលវេលាច្រើនជាងមុនក្នុងការជួយបង្រៀនកូន ឬ ក្មួយរបស់ពួកគេ។ សម្រាប់ពួកគេភាគច្រើនដែលមានកូន ឬ ក្មួយលើសពីពីរនាក់កំពុងសិក្សា ការរៀនតាមប្រព័ន្ធអេឡិចត្រូនិកនេះ គឺជាការបន្ថែមបន្ទុកទ្វេរដងទៅលើពួកគេ។ ម្នាក់ក្នុងចំណោមឪពុកម្ដាយ ឬ អាណាព្យាបាល បានលើកឡើងនូវក្ដីបារម្ភទៅលើគុណភាពនៃការអប់រំ និងទំនាក់ទំនងរបស់កូនចៅរបស់គាត់នៅក្នុងសង្គមនៅអំឡុងពេលរៀនតាមប្រព័ន្ធអេឡិចត្រូនិកនេះ។

> *" ជាយោបល់ខ្ញុំ ការសិក្សាតាមរយៈប្រព័ន្ធអេឡិចត្រូនិកបានផ្ដល់ប្រយោជន៍ដល់អ្នកសិក្សាមួយចំនួនដែលចេះប្រើប្រាស់វា និងប្រើវាដោយភាពត្រឹមត្រូវ។ ប៉ុន្តែអ្នកដែលមិនចេះប្រើ ឬ មិនទាន់យល់ពីផលប៉ះពាល់របស់វា ជាពិសេសកុមារ គឺពិតជាគ្រោះថ្នាក់ខ្លាំងណាស់នៅពេលដែលប្រើប្រាស់ជាមធ្យោបាយនៃការសិក្សា វាអាចធ្វើឲ្យក្មេងប្រែក្លាយជាមនុស្សមួយផ្សេងទៀត ឬ បាត់បង់ទំនាក់ទំនងក្នុងសង្គម។ "*

> *"សាលា ឬ ក្រសួងមិនគួរបន្ថែមបន្ទុកអោយគ្រូ និង សិស្ស ក្នុងអំឡុងពេលដែលមានការលំបាកដោយសារកូវីដ១៩នេះទេ។ មនុស្សត្រូវការពេលវេលាថែទាំគ្រួសារ តែត្រូវមកបន្ថែមបន្ទុកនេះមួយទៀត។ ការបង្រៀនកូន គឺជារឿងធម្មតាតែមិនមែនចាំបាច់ត្រូវធ្វើដោយសារពេលវេលាមួយនេះ នៅពេលដែលទាំងអស់គ្នាកំពុងត្រូវការភាពអត់ធ្មត់និងរក្សាចិត្តគំនិតគិតអំពីជីវភាពនិងសុខភាពគ្រួសារជារឿងសំខាន់។"*

## ៤. មតិយោបល់របស់សិស្ស និស្សិត និង ឪពុកម្តាយ ឬ អាណាព្យាបាល

*"សំណូមពរដល់សាលារៀនរដ្ឋ និងឯកជន នៅក្នុងគ្រាលំបាកនេះ មេត្តាផ្តល់ការគាំទ្រទៅដល់សិស្សានុសិស្ស។ ពេលខ្លះ គ្រូបង្រៀនតាមអនឡាញតែមួយម៉ោង រួចឲ្យសិស្សទទួលខុសត្រូវរៀនដោយខ្លួនឯងពេញមួយថ្ងៃ។ នេះគឺជាកំហុសឆ្គងដ៏ធ្ងន់ធ្ងររបស់គ្រូបង្រៀនទាំងនោះ ដែលពួកគេតែងតែមានអារម្មណ៍ថា សិស្សគួរតែទទួលខុសត្រូវដោយខ្លួនឯង។ សូម្បីតែសាលាដែលខ្ញុំបញ្ជូនកូនៗទៅរៀនត្រឹមថ្នាក់ទី៥ ត្រូវចំណាយរហូតដល់ ៥០០០ដុល្លារ ក៏ដោយ ក៏គុណភាពនៃការបង្រៀនតាមប្រព័ន្ធអនឡាញនេះ គឺមិនអាចទទួលយកបាននោះទេ។"*

ទោះជាឪពុកម្តាយ ឬ អាណាព្យាបាលមួយចំនួន បង្ហាញថាពួកគេជឿជាក់ទៅលើការអប់រំក្នុង ថ្នាក់រៀនជាជាងការរៀនតាមប្រព័ន្ធនេះយ៉ាងណាក្តី មានការស្នើឲ្យរដ្ឋ (ក្រសួងអប់រំ យុវជន និងកីឡា) បន្តផ្តល់ការគាំទ្រ និងឧបត្ថម្ភធនដល់ការសិក្សាតាមប្រព័ន្ធនេះ ពិសេសនៅក្នុងអំឡុងពេលជំងឺកូវីដ១៩ ឲ្យបានទូលំទូលាយ។ មានការស្នើផងដែរពីសំណាក់ឪពុកម្តាយ ឬ អាណាព្យាបាលទៅដល់សាលាឯកជន និងរដ្ឋបញ្ចុះតម្លៃសិក្សាសម្រាប់កូនៗរបស់ពួកគេ។ ពួកគេយល់ឃើញថា ទាំងគុណភាព និងពេលវេលាមិនសមស្របជាមួយតម្លៃដែលពួកគេចំណាយ បើប្រៀបធៀបទៅនឹងការរៀនក្នុងថ្នាក់។ សិស្ស និស្សិតមួយចំនួនសំណូមពរឲ្យមានការលើកលែងការបង់ថ្លៃលើសេវាអ៊ិនធើណែត និងជម្រុញឲ្យប្រព័ន្ធនេះគ្របដណ្តប់ទូទាំងប្រទេស។

ឪពុកម្តាយ ឬ អាណាព្យាបាលមួយចំនួន ក៏បានលើកឡើងផងដែរថា ការរៀនតាមប្រព័ន្ធអេឡិចត្រូនិកនេះអាចប្រើប្រាស់បានតែរយៈពេលខ្លីសម្រាប់សិស្សសិក្សា។ ប៉ុន្តែ វាមិនអាចប្រើប្រាស់ក្នុងរយៈពេលវែងនោះទេ។ គុណភាពនៃការអប់រំតាមរយៈប្រព័ន្ធនេះ ត្រូវបានចោទជាសំណួរពីសំណាក់ឪពុកម្តាយ ឬ អាណាព្យាបាលមួយចំនួន។ សម្រាប់សិស្ស និស្សិតមួយចំនួនទៀតដែលពុំមានលទ្ធភាពដោយសារកត្តាជីវភាព ឬ ត្រូវផ្តល់អទិភាពការចំណាយទៅលើអាហារ ឬ សុខភាពគ្រួសារ ពិសេសនៅក្នុងអំឡុងជំងឺ កូវីដ១៩ ការសិក្សាតាមប្រព័ន្ធនេះហាក់មិនបានជួយគាំទ្រដល់ការពង្រឹងសមត្ថភាព គុណភាពអប់រំ ឬ ជំនួយដល់ការទទួលបានការអប់រំរបស់ពួកគេក្នុងគ្រានេះទេ។ ឪពុកម្តាយ ឬ អាណាព្យាបាលមួយចំនួន បង្ហាញពីក្តីបារម្ភរបស់ពួកគេចំពោះការធ្លាក់ចុះនៃទំនាក់ទំនងរវាងសិស្សានុសិស្សជាមួយគ្រូ និងមិត្តរួមថ្នាក់ពីការរៀនតាមប្រព័ន្ធអេឡិចត្រូនិកនេះដែលជាផ្នែកមួយយ៉ាងសំខាន់នៃការអប់រំ។

ផ្សព្វផ្សាយឆ្នាំ២០២០

ស្វែងរកព័ត៌មានបន្ថែមតាមរយៈ

www.sac.unitedsisterhood.org

Social Action for Community and Development

Social Action for Community and Development SACD

ផ្ទះលេខ១៦៨ ផ្លូវ១0BT សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ (+៨៥៥) ១៧ ៤៥៤ ៥៣៥
អ៊ីម៉ែល chreksophea@gmail.com